**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ:...៤៧០...សជណ...

**សូមជម្រាបជូន**

**ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត**

**កម្មវត្ថុ** : អំពីរបាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

**យោង** : -សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៤ សណន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន

-សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ ០២ សរណន ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ ស្តីពីការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការបំពេញការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាប **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបអំពីគោលការណ៍នៃការធ្វើរបាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងារ និងទម្រង់របាយការណ៍សម្រាប់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ធ្វើរបាយការណ៍បញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីបូកសរុបរាយការណ៍ជូនរាជរដ្ឋាភិបាលដូចខាងក្រោម៖

១- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងារទៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំនីមួយៗ ផ្អែកលើទម្រង់របាយការណ៍ដូចមានជូនភ្ជាប់មកជាមួយនេះ។ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ក៏អាចប្រើប្រាស់ទម្រង់របាយការណ៍នេះសម្រាប់ណែនាំដល់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ធ្វើរបាយការណ៍បូកសរុបផងដែរ។ របាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងារចុះមូលដ្ឋានរាជធានី ខេត្តត្រូវបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី ដូចខាងក្រោម៖

- របាយការណ៍ប្រចាំត្រីមាស ត្រូវបញ្ជូនមកយ៉ាងយូរត្រឹមថ្ងៃទី២៥ ខែទីបី នៃត្រីមាសនីមួយៗ
- របាយការណ៍ប្រចាំឆមាសទី១ មានរួមបញ្ចូលនូវលទ្ធផលការងារត្រីមាសទី២ ត្រូវបញ្ជូនមកយ៉ាងយូរត្រឹមថ្ងៃទី២៥ ខែទីប្រាំមួយ នៃឆមាសទី១

– របាយការណ៍ប្រចាំឆ្នាំ មានរួមបញ្ចូលនូវលទ្ធផលការងារត្រីមាសទី៤ ត្រូវបញ្ជូនមកយ៉ាងយូរត្រឹមថ្ងៃទី២៥ ខែធ្នូ នៃឆ្នាំនីមួយៗ។

២- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ត្រូវសហការ និងសម្របសម្រួល ឬណែនាំលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន រៀបចំរបាយការណ៍ដូចមានចែងក្នុងចំណុចទី១ខាងលើ ហើយត្រូវស្នើសុំការសម្រេចពីប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី។ ទន្ទឹមនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការណែនាំដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីសហការឬដឹកនាំលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានដើម្បីធ្វើរបាយការណ៍បូកសរុបបញ្ជូនមករាជធានីខេត្ត និងណែនាំឱ្យក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានឃុំ សង្កាត់ ធ្វើរបាយការណ៍ឱ្យទៀងទាត់ផ្ញើមកថ្នាក់ក្រុង ស្រុក ខណ្ឌសាមី ដើម្បីបូកសរុបវាយតម្លៃ និងតាមដានត្រួតពិនិត្យការងារ។

៣- ក្រៅពីរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ទីស្តីការគណៈរដ្ឋមន្ត្រីអាចស្នើសុំឱ្យក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ធ្វើរបាយការណ៍តាមតម្រូវការចាំបាច់នៃការងារ។

៤- ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត អាចធ្វើសេចក្តីរាយការណ៍សុំយោបល់ដឹកនាំដោយផ្ទាល់ពី **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ទៅតាមតម្រូវការចាំបាច់នៃការងារ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងសហការចាត់ចែងអនុវត្តតាមខ្លឹមសារដូចបានជម្រាបជូនខាងលើ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវសេចក្តីគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃ ចន្ទ ១៥ រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ